# I. រដ្ឋសភា

# ច្បាប់

## ច្បាប់ ស្តីពីការកែប្រែ

## មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ

## នៃព្រះរាជាណាចក្រកម្ពុជា

មាត្រាតែមួយ:-មាត្រា២៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវកែប្រែដូចតទៅ៖

មាត្រា ២៨ ថ្មី:- ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។ ក្នុងពេលដែល ព្រះមហាក្សត្រប្រចួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេសក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចព្រះហស្តលេខា នៅលើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយ ព្រះរាជសារ ប្រគល់សិទ្ធិ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ១៤ ខែកក្កដា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសមញ្ញសម័យពិសេស
ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី
ហត្ថលេខា និង ត្រា
លោយ ស៊ីមឈាង

# II ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី១១ ជំពូកទី២ ស្តីអំពី ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣

បង្គាប់

មាត្រា ១ : ប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ១៩៩៤ ។

មាត្រា ២ : ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជចំណារ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ត្រា

**ជា ស៊ីម**